**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ ៖ ០៤៥/២០ ក.ប / ស.ជ.ណ.ខ.ល

# សេចក្តីជូនដំណឹង

## ស្តីពី

## វិធានការការពារបងប្អូនពលករ ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ និងការផ្អាកការបញ្ជូនពលករ MOU និងពលករតាមរដូវកាលទៅធ្វើការងារនៅប្រទេសថៃជាបណ្តោះអាសន្ន ក្នុងអំឡុងពេលការរាតត្បាតជំងឺកូវីដ-១៩ នៅខេត្តសាមុតសាខននៃប្រទេសថៃ

យោងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការការពារសុខភាព សុវត្ថិភាព និងជីវិតរបស់បងប្អូនពលករខ្មែរ ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ក្នុងអំឡុងពេលមានការរាតត្បាតជំងឺកូវីដ-១៩ ក្នុងខេត្តសាមុតសាខននៃប្រទេសថៃនោះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដូចខាងក្រោម៖

### ក. សម្រាប់បងប្អូនពលករដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ

១. សូមអនុវត្តឱ្យបានល្អនូវអនុសាសន៍របស់ **សម្តេចតេជោ ហ៊ុន សែន** ជាពិសេសគឺត្រូវរក្សាភាពនឹងនរ និងជឿជាក់លើសមត្ថកិច្ចថៃក្នុងការគ្រប់គ្រង បង្ការ និងព្យាបាលជំងឺកូវីដ-១៩។

២. សូមរក្សាប្រក្រតីភាពការងារ កុំផ្លាស់ប្តូរកន្លែងស្នាក់នៅ ឬកន្លែងធ្វើការងារពីខេត្តមួយទៅខេត្តមួយ ដែលខុសនឹងបម្រាមរបស់អាជ្ញាធរថៃ។

៣. ត្រូវចូលរួមសហការ និងគោរពឱ្យបាននូវរាល់បទបញ្ជា និងវិធានការសុខាភិបាលដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចថៃ និងនិយោជកថៃ។

៤. ត្រូវអនុវត្តតាមការណែនាំ ឬសេចក្តីជូនដំណឹងរបស់ស្ថានឯកអគ្គរាជទូត ឬអគ្គកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ ប្រសិនជាមាន។

៥. ត្រូវលាងដៃជាមួយនឹងសាប៊ូ ឬជែលឱ្យបានញឹកញាប់ ពាក់ម៉ាស់ និងរក្សាអនាម័យឱ្យបានល្អ និងជាប្រចាំនៅកន្លែងធ្វើការងារ និងកន្លែងស្នាក់នៅ ព្រមទាំងកុំចេញទៅកន្លែងសាធារណៈដែលមានមនុស្សច្រើន។

៦. ត្រូវទាក់ទងទៅស្ថានឯកអគ្គរាជទូត ឬអគ្គកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាជាបន្ទាន់ក្នុងករណីមានបញ្ហា។

៧. ចំពោះមុខក្រសួងបាននឹងកំពុងទំនាក់ទំនងជាមួយក្រសួងការងារថៃ និងបានស្នើភាគីថៃសម្រួលការងារឯកសារផ្សេងៗដល់បងប្អូនពលករដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃឱ្យបានភាពស្របច្បាប់ជាបណ្តោះអាសន្នក្នុងអំឡុងពេលមានការរាតត្បាតជំងឺកូវីដ-១៩នេះ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣) ៨៨ ៨៣ ៧៨ និងទូរសារៈ(០២៣) ៨៨ ២៧ ៦៥

**ខ. សម្រាប់បងប្អូនពលករ ដែលចាំបាច់ត្រូវវិលត្រឡប់មកស្រុកកំណើតវិញ**

១. ប្រសិនជាចាំបាច់ត្រូវត្រឡប់មកស្រុកកំណើតវិញនោះ ត្រូវជ្រើសរើសច្រកណាមួយក្នុងចំណោម ច្រកអូរស្មាច់ ច្រកដូង និងច្រកប៉ោយប៉ែត ជាដាច់ខាត ដែលនៅទីនោះរាជរដ្ឋាភិបាលមានរៀបចំការត្រួតពិនិត្យសុខភាព ដើម្បីការពារសុខភាពរបស់បងប្អូន ក៏ដូចជាបង្ការ និងការពារសុខភាពក្រុមគ្រួសាររបស់បងប្អូនដែលនៅស្រុកកំណើត។

២. ត្រូវអនុវត្តវិធានការត្រួតពិនិត្យសុខភាព និងត្រូវធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ ទៅតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ចនៅតាមច្រកព្រំដែន។

៣. ត្រូវប្រើប្រាស់រថយន្តដែលកំណត់ដោយមណ្ឌលចត្តាឡីស័ក ក្រោយពេលបញ្ចប់ការធ្វើចត្តាឡីស័ក ត្រឡប់ទៅភូមិកំណើត។

៤. ត្រូវជូនដំណឹងដល់អាជ្ញាធរភូមិ ឃុំ និងអ្នកជិតខាងឱ្យជ្រាបថាខ្លួនទើបវិលត្រឡប់មកពីប្រទេសថៃ។

៥. ក្នុងករណីមានបញ្ហាជីវភាពរស់នៅប្រចាំថ្ងៃ ត្រូវជូនដំណឹងទៅអាជ្ញាធរភូមិ ឃុំរបស់ខ្លួន ដើម្បីទទួលបានសេវាអន្តរាគមន៍នានារបស់រាជរដ្ឋាភិបាល។

៦. សូមចុះឈ្មោះជាមួយ ទីភ្នាក់ងារជាតិមុខរបរនិងការងារ តាមរយៈ www.nea.gov.kh ឬទូរសព្ទ ០១៧ ៨៥០ ៦៥៦ ប្រសិនជាបងប្អូនមានបំណងស្វែងរកការងារធ្វើក្នុងស្រុក និងសូមចុះឈ្មោះស្វែងរកឱកាសការងារជាមួយភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់ ប្រសិនជាមានបំណងស្វែងរកការងារធ្វើនៅប្រទេសណាមួយផ្សេង។

៧. សូមចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដោយឥតបង់ថ្លៃនៅគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈណាមួយរបស់ក្រសួង ដែលនៅជិតផ្ទះរបស់ខ្លួន។

**គ. សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជន និងមន្ត្រីពាក់ព័ន្ធ**

១. ផ្អាកការបញ្ជូនពលករ MOU និងពលករតាមរដូវកាលទៅប្រទេសថៃរហូតដល់មានការជូនដំណឹងជាថ្មី។

២. ត្រូវបន្តទំនាក់ទំនងជាមួយនិយោជកថៃ ឬសមាគមនិយោជកថៃ និងអាជ្ញាធរថៃ ក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ចកម្ពុជាដើម្បីជួយសម្រួលដល់ពលករ ក្នុងករណីចាំបាច់តាមការសម្រេចរបស់រាជរដ្ឋាភិបាល។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមបងប្អូនពលករ ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ទីភ្នាក់ងារជ្រើសរើសឯកជន និងមន្ត្រីពាក់ព័ន្ធជ្រាប និងចូលរួមអនុវត្តសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ចន្ទ ៧ កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ [illegible] ឆ្នាំ ២០២០

រដ្ឋមន្ត្រី

**អ៊ិត សំហេង**